ទីស្តីការក្រសួងយុត្តិធម៌
លេខ ១១៧ សរ.រវ-៩៧

# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

## សេចក្តីបង្គាប់

## ស្តីពីការអនុវត្តសាលក្រម សាលដីកាស្ថាពរ និងសេចក្តីសម្រេចផ្សេងៗរបស់តុលាការ
## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

សូមជម្រាបអស់លោកប្រធានតុលាការនិងព្រះរាជអាជ្ញាអមតុលាការខេត្ត-ក្រុងថា ដោយសព្វថ្ងៃយើងមិនទាន់មានច្បាប់ប្រគល់សមត្ថកិច្ចទៅឱ្យអង្គការណាមួយ ដើម្បីយកសាលក្រមឬសាលដីកាស្ថាពរឬដីកាផ្សេងៗទៀតរបស់តុលាការគ្រប់ជាន់ថ្នាក់ ទៅអនុវត្តតាមច្បាប់ស្តីពីវិធីអនុវត្តសាលក្រមនៅឡើយ ហើយកន្លងមកការអនុវត្តសេចក្តីសម្រេចទាំងនេះ តែងតែជួបប្រទះនឹងភាពរឹងរូស រហូតដល់មានការទប់ទល់ប្រឆាំងដោយប្រដាប់អាវុធធ្វើឱ្យប៉ះពាល់ដល់របៀបរៀបរយសាធារណៈក្នុងសង្គមបង្កើតជាបទល្មើសមជ្ឈិមឬឧក្រិដ្ឋថែមទៀត

ដោយព្រះរាជអាជ្ញាជាមន្ត្រីនគរបាលយុត្តិធម៌ មានតួនាទីជាអ្នកដឹកនាំកិច្ចប្រតិបត្តិការទាំងឡាយនៃមន្ត្រីនគរបាលយុត្តិធម៌និងបង្រ្កាបបទល្មើសព្រហ្មទណ្ឌ ស្វែងរកជនល្មើស កេណ្ឌកំលាំងសាធារណៈរុករកនិងប្រមូលភស្តុតាងនៃអំពើល្មើស មានសិទ្ធិធ្វើការឆែកឆេររឹបអូសវត្ថុតាង និងឃាត់ខ្លួនជនល្មើសក្នុងករណីមានបទមជ្ឈិម ឬ ឧក្រិដ្ឋជាក់ស្តែងកើតឡើង ដើម្បីរក្សាការពាររបៀបរៀបរយសាធារណៈក្នុងសង្គម ។

ដោយយោលតាមសភាពការណ៍ខាងលើនេះ ក្រសួងយុត្តិធម៌សម្រេចប្រគល់សមត្ថកិច្ចជូនព្រះរាជអាជ្ញាដឹកនាំអនុវត្តដោយផ្ទាល់ជាបណ្តោះអាសន្ននូវសេចក្តីសម្រេចទាំងអស់ និងដីកាផ្សេងៗទៀតរបស់តុលាការគ្រប់ជាន់ថ្នាក់ក្នុងរង្វង់សមត្ថកិច្ចដែនដីរបស់ខ្លួន ទំរាំមានច្បាប់កំណត់អំពីបញ្ហានេះ ប្រសិនបើមានការស្នើសុំត្រឹមត្រូវតាមច្បាប់ពីអ្នកឈ្នះក្តីឬពីអ្នកទទួលសិទ្ធពីអ្នកឈ្នះក្តី ។

ប្រធានតុលាការ ឬចៅក្រមដែលប្រធានតុលាការចាត់តាំងឱ្យទទួលភារកិច្ចក្នុងរឿងក្តីណាមួយមានតួនាទីជាអ្នកត្រួតពិនិត្យរួចវិនិច្ឆ័យសេចក្តីនៅពេលណាដែលមានពាក្យបណ្តឹងតវ៉ា អំពីចំណុចខ្វះខាតនៃការរនុវត្តសាលក្រមឬសាលដីកា ពីជនដែលត្រូវរឹបអូស ពីម្ចាស់បំណុលនៃជនដែលត្រូវរឹបអូស ឬពីតតីយជនណាមួយដែលមានផលប្រយោជន៍ក្នុងរឿងនោះ ។

ក្រសួងយុត្តិធម៌ សូមលោកព្រះរាជអាជ្ញា និងលោកប្រធានតុលាការគ្រប់ខេត្ត-ក្រុង អនុវត្តតាមបញ្ជានេះចាប់ពីថ្ងៃនេះតទៅ ។

<u>អ្នកទទួល</u>
-ប្រធានតុលាការខេត្ត-ក្រុង
-ព្រះរាជអាជ្ញាអមតុលាការខេត្ត-ក្រុង
(ដើម្បីរនុវត្ត)
-ក្រសួងមហាផ្ទៃ
-ប្រធានតុលាការកំពូល
-អគ្គព្រះរាជអាជ្ញាអមតុលាការកំពូល
-អភិបាលខេត្ត-ក្រុង
-ប្រធានសាលាឧទ្ធរណ៍
-អគ្គព្រះរាជអាជ្ញាអបសាលាឧទ្ធរណ៍
-នាយកដ្ឋានព្រហ្មទណ្ឌ និងរដ្ឋប្បវេណី
-នាយកដ្ឋានបុគ្គលិក និងបណ្តុះបណ្តល ក្រសួងយុត្តិធម៌
-មន្ទីរក្រសួងយុត្តិធម៌
-តុលាការយោធា
-ព្រះរាជអាជ្ញាអមតុលាការយោធា
-គណៈមេធាវី -ដើម្បីជ្រាប
-មជ្ឈមណ្ឌលតម្កល់ឯកសារ (ដើម្បីជ្រាប)

ធ្វើនៅភ្នំពេញ ថ្ងៃទី៣១ ខែមករា ឆ្នាំ១៩៩៧

**រដ្ឋមន្ត្រី**

**ចែម ស្នួន**